# ថវិកាក្នុងការផលិតសាច់រឿងសម្រាប់អ្នកសារព័ត៌មាន

## សាវតា

ការរស់នៅសមរម្យ និងសេវាសាធារណៈដែលអាចជឿទុកចិត្តបានគឺជាតម្រូវការមូលដ្ឋានរបស់ប្រជាពលរដ្ឋ។ នៅក្នុងស្ថានភាពជាក់ស្តែង មានបញ្ហាមួយចំនួនបានកើតឡើងទាក់ទងនឹងប្រសិទ្ធភាពនៃសេវាសុខភាពសាធារណៈ គុណភាពនៃប្រព័ន្ធអប់រំសាធារណៈ និងតម្លាភាពនៃចំណូល និងចំណាយរបស់រដ្ឋបាលឃុំសង្កាត់ ដែលនៅតាម បណ្តាសហគមន៍នានា។ ថ្វីបើការអភិវឌ្ឍសង្គមហាក់មានដំណើរការទៅមុខ ប៉ុន្តែការផ្សព្វផ្សាយព័ត៌មានអំពីវឌ្ឍនភាពនៃគណនេយ្យភាពសង្គមនូវមិនទាន់គ្រប់គ្រាន់ និងផ្តល់ទិដ្ឋភាពពេញលេញ។ បញ្ហាកង្វះព័ត៌មាននេះ ធ្វើឱ្យយើងពុំអាចមើលឃើញច្បាស់លាស់អំពីការរីកចម្រើន និងចន្លោះខ្វះខាតដែលគួរត្រូវបានបំពេញ ដែលនាំទៅរកសេចក្តីសម្រេចចិត្ត និងការតាក់តែងគោលនយោបាយដែលមិនបានឆ្លុះបញ្ចាំងពេញលេញទៅលើស្ថានភាពជាក់ស្តែង។ បញ្ហានេះអាចនឹងបង្អាក់ ឬធ្វើឱ្យមានភាពយឺតយ៉ាវក្នុងការអភិវឌ្ឍសង្គម។ ដូច្នេះ យើងគួរយកចិត្តទុកដាក់លើកកម្ពស់ និងជំរុញឱ្យមានការផ្សព្វផ្សាយព័ត៌មាន និងការសិក្សាស្រាវជ្រាវអំពីបញ្ហាទាក់ទងនឹងគណនេយ្យភាពសង្គមឱ្យកាន់តែច្រើន។

## កម្មវត្ថុ

អង្គការទិន្នន័យអំពីការអភិវឌ្ឍ (អូឌីស៊ី) សហការជាមួយអង្គការ Internews តាមរយៈគម្រោងការច្នៃប្រឌិតថ្មីសម្រាប់គណនេយ្យភាពសង្គមនៅកម្ពុជា (ISAC) នឹងផ្តល់ថវិកាសម្រាប់ផលិតសាច់រឿងចំនួនបួនដល់អ្នកសារព័ត៌មានក្នុងការផលិតអត្ថបទរឿងដោយផ្អែកលើទិន្នន័យដែលផ្សារភ្ជាប់ទៅនឹងគណនេយ្យភាពសង្គមនៅប្រទេសកម្ពុជា ដែលជាការបំពេញបន្ថែមលើវគ្គបណ្តុះបណ្តាលអក្ខរកម្មទិន្នន័យដែលបានធ្វើឡើងនាពេលថ្មីៗនេះសម្រាប់អ្នកសារព័ត៌មាន។

## ប្រធានបទ

ប្រធានបទនៃសាច់រឿងត្រូវតែពាក់ព័ន្ធទៅនឹងមូលបទគណនេយ្យភាពសង្គមនៅប្រទេសកម្ពុជា ហើយសាច់រឿងដែលទាក់ទងនឹងសេវាទាំងបីដូចជា រដ្ឋបាលឃុំ សង្កាត់ សាលាបឋមសិក្សា និងមណ្ឌលសុខភាពត្រូវបានលើកទឹកចិត្តឱ្យសរសេរ ប៉ុន្តែមិនកំណត់ដាច់ខាតនោះទេ។

## លក្ខខណ្ឌដើម្បីចូលរួម

- ជាអ្នកសារព័ត៌មានបម្រើការងារនៅប្រព័ន្ធផ្សព្វផ្សាយណាមួយ ឬជាអ្នកសារព័ត៌មានឯករាជ្យ

USAID ជំនួយពីប្រជាជនអាមេរិក | fhi360 | Internews Local voices. Global change. | អង្គការទិន្នន័យអំពីការអភិវឌ្ឍ Open Development Cambodia

- មានការប្តេជ្ញាចិត្ត និងមានពេលវេលាគ្រប់គ្រាន់ ដើម្បីផលិតសាច់រឿងជុំវិញគណនេយ្យភាពសង្គម នៅប្រទេសកម្ពុជាក្នុងរយៈពេលដែលបានកំណត់
- ផ្តល់អាទិភាពដល់អ្នកសារព័ត៌មានដែលបានចូលរួមវគ្គបណ្តុះបណ្តាលអក្ខរកម្មទិន្នន័យសម្រាប់អ្នកសារព័ត៌មាន
- មានឆន្ទៈ និងបើកចិត្តក្នុងការទទួលយក និងអនុវត្តទៅតាមសេចក្តីណែនាំនៃការផលិតសាច់រឿង ទិន្នន័យដែលកំណត់ដោយគ្រូបង្គោលផ្នែកទិន្នន័យ និងសាច់រឿង
- មានជំនាញទិន្នន័យចាំបាច់ដូចជា ការស្វែងរកទិន្នន័យ ការវិភាគទិន្នន័យ និងទស្សនីយកម្មទិន្នន័យ សម្រាប់ការផលិតសាច់រឿង

**របៀបដាក់ពាក្យ**

អ្នកដាក់ពាក្យត្រូវបំពេញរាល់ព័ត៌មានដែលត្រូវការនៅក្នុងទម្រង់ពាក្យស្នើសុំ។

*សូមចុចលើតំណភ្ជាប់ខាងក្រោមនេះដើម្បីដាក់ពាក្យ*

https://forms.gle/aoEcMH8gwb3Eg2U3A

**អត្ថប្រយោជន៍**

- បេក្ខជននឹងទទួលបានប្រាក់ឧបត្ថម្ភចំនួន 1,000 ដុល្លារអាមេរិកសម្រាប់ការផលិតសាច់រឿង (រាល់ការចំណាយលើការផលិតរឿងត្រូវបានរួមបញ្ចូលនៅក្នុងថវិកានេះ)
- បេក្ខជននឹងទទួលបានការគាំទ្រពីគ្រូបង្គោលផ្នែកទិន្នន័យ និងសាច់រឿង
- ឱកាសក្នុងការពង្រីក និងពង្រឹងចំណេះដឹងលើការផលិតអត្ថបទរឿងដោយផ្អែកលើទិន្នន័យ
- នៅពេលដែលបានបញ្ចប់ បេក្ខជននឹងត្រូវបានជួយគាំទ្រក្នុងការរចនារៀបចំអត្ថបទរឿងឱ្យមានលក្ខណៈអន្តរកម្ម (Interactive visual storytelling) នៅពេលធ្វើការផ្សព្វផ្សាយ
- សាច់រឿងនឹងត្រូវបានផ្សាយនៅលើបណ្តាញផ្សព្វផ្សាយរបស់បេក្ខជន និងសារព័ត៌មាន CamboJA

**លក្ខណៈវិនិច្ឆ័យ**

- ប្រធានបទដែលពាក់ព័ន្ធទៅនឹងមូលបទនៃសាច់រឿង
- ការផលិតសាច់រឿងត្រូវតែប្រើប្រាស់ និងផ្អែកលើទិន្នន័យ
- សាច់រឿងដែលមានលក្ខណៈជាការលើកកម្ពស់ការយល់ដឹង បង្កើតឱ្យមានការចូលរួម ទាក់ទាញការយកចិត្តទុកដាក់ បំផុសឱ្យមានការពិភាក្សា និងជំរុញឱ្យមានសកម្មភាព
- សាច់រឿងត្រូវតែមានភាពសត្យានុម័ត ជាជាងផ្តោតលើការតស៊ូមតិ ឬបម្រើផលប្រយោជន៍នយោបាយ

**ដំណាក់កាល**

- ថ្ងៃទី ១ សីហា ២០២៣ ប្រកាសជ្រើសរើសបេក្ខភាពសម្រាប់ថវិកាសរសេររឿង
- ថ្ងៃទី ២០ សីហា ២០២៣ បិទការទទួលពាក្យសុំចូលរួម
- ថ្ងៃទី ២៧ សីហា ២០២៣ ពិនិត្យបេក្ខភាព & ការសម្ភាសន៍បេក្ខជន & ប្រកាសលទ្ធផល
- ថ្ងៃទី ៣១ សីហា ២០២៣ ការផលិតសាច់រឿង និងការណែនាំ
- ថ្ងៃទី ៣១ តុលា ២០២៣ សេចក្តីព្រាងចុងក្រោយសម្រាប់ការបោះពុម្ព